**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ២៥៣ ដនស/អសណ

ថ្ងៃសុក្រ ៩កើត ខែអស្សុជ ឆ្នាំរោងឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០២៤

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# លិខិតអនុញ្ញាតសាងសង់

**យោង** : - ព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០១៩ ប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់

- អនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- អនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់
- ប្រកាសអន្តរក្រសួងលេខ ៣៥៦ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១៩ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតអនុញ្ញាតសាងសង់ និងប្លង់ស្ថាបត្យកម្មលេខ ៣៨៤ ដនស/អសណ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០២៣ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០២៤ របស់លោកស្រី **សូ ស្រីមុំ** (ជាប្រពន្ធលោក **ហួត ចាន់យ៉ារ៉េត**)

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុញ្ញាតឱ្យកែសម្រួលប្លង់ស្ថាបត្យកម្មអគារភូមិគ្រឹះប្រភេទ A ចំនួន ០១ ខ្នង កម្ពស់អតិបរមា ៣៦,៦៥ ម៉ែត្រ មានជាន់ក្រោមដី ០១ ជាន់ ជាន់ផ្ទាល់ដី ជាន់ឡៅតឿ ជាន់ទី ០១ ដល់ជាន់ទី ០៥ ដំបូលទៃរ៉ាស់ និងប្រក់ក្បឿង ភូមិគ្រឹះប្រភេទB ចំនួន ០១ ខ្នង កម្ពស់អតិបរមា ១៨,៤៤ ម៉ែត្រ មានជាន់ក្រោមដី ០១ ជាន់ ជាន់ផ្ទាល់ដី ជាន់ទី ០១ ជាន់ទី ០២ ដំបូលទៃរ៉ាស់ ភូមិគ្រឹះប្រភេទC ចំនួន ០១ ខ្នង កម្ពស់អតិបរមា ១៨,៤៤ ម៉ែត្រ មានជាន់ក្រោមដី ០១ ជាន់ ជាន់ផ្ទាល់ដី ជាន់ទី ០១

ជាន់ទី ០២ ដំបូលតេរ៉ាស់ ភូមិគ្រឹះប្រភេទ D ចំនួន ០១ ខ្នង កម្ពស់អតិបរមា ៧,៩០ ម៉ែត្រ មានជាន់ផ្ទាល់ដី ជាន់ទី ០១ ដំបូលតេរ៉ាស់ មានផ្ទៃក្រឡាសំណង់សរុប **១៦.៣៦៩,៨១** ម៉ែត្រការ៉េ មានសន្ទស្សន៍ប្រើប្រាស់ដី ០,៩១ នៅលើដីឡូត៍ទំហំ **១៨.៣០៨,០០** ម៉ែត្រការ៉េ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ **១២០៨០៤០៥-០៦២៧** ភូមិព្រៃខ្លា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ របស់លោកស្រី **សូ ស្រីមុំ** (ជាប្រពន្ធលោក **ហ្វួត ចាន់យ៉ារ៉េត**) ដោយម្ចាស់សំណង់ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ÷

១. ត្រូវរៀបចំឱ្យមានសួនជ្រាបទឹកឱ្យបានយ៉ាងតិច ៣០ % នៃផ្ទៃដីឡូត៍ដែលនៅសល់ពីការសាងសង់ ត្រូវដាំដើមឈើ និងរុក្ខជាតិបៃតងឱ្យបានអតិបរមា ត្រូវរៀបចំផែនការសាងសង់ និងប្រើប្រាស់អគារសន្សំសំចៃថាមពល និងត្រូវប្រើប្រាស់សម្ភារៈសំណង់សមស្របដែលរួមចំណែកដល់គោលនយោបាយជាតិអភិវឌ្ឍន៍បៃតងរបស់រាជរដ្ឋាភិបាល។

២. ហាមប្រើប្រាស់ផ្លូវ ចិញ្ចើមផ្លូវ ទីធ្លាសាធារណៈជាចំណតយានយន្ត កន្លែងទុកដាក់សម្ភារៈសំណង់ និងឧបករណ៍សំណង់ គ្រឿងចក្រសាងសង់ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

៣. ត្រូវរៀបចំឱ្យមានពន្លឺ និងខ្យល់ចេញចូលគ្រប់គ្រាន់ក្នុងអគារ និងក្នុងបន្ទប់រស់នៅស្របតាមបទដ្ឋានបច្ចេកទេស និងត្រូវបំពាក់សម្ភារៈសំណង់ដែលមិនប៉ះពាល់ដល់សុវត្ថិភាពសាធារណៈ សុខភាព បរិស្ថាន និងសង្គម និងសោភណភាពអគារត្រូវមានលក្ខណៈស្ថាបត្យកម្មល្អសមស្រប។

៤. ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងសំណល់រឹង-រាវ រៀបចំអាងប្រព្រឹត្តកម្មទឹកកខ្វក់ បំពាក់ម៉ាស៊ីនចម្រោះទឹកកខ្វក់ ប្រព័ន្ធលូស្របតាមមុខងារប្រើប្រាស់អគារមុនបង្ហូរចេញ ប្រព័ន្ធទឹកស្អាត ប្រព័ន្ធអគ្គិសនី ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដោយមានការពិនិត្យយល់ព្រមពីសមត្ថកិច្ចជំនាញពាក់ព័ន្ធ ព្រមទាំងប្រើប្រាស់បច្ចេកទេសសាងសង់សមស្រប ដើម្បីធានាសុវត្ថិភាពដល់សំណង់ជិតខាង ការពារបរិស្ថាន សុវត្ថិភាពសាធារណៈ និងសុខុមាលភាពសង្គម។

៥. ត្រូវសិក្សាប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យស្របតាមបទដ្ឋានបច្ចេកទេស និងមានការបញ្ជាក់ទទួលស្គាល់ពីអគ្គស្នងការដ្ឋាននគរបាលជាតិ។

៦. ត្រូវអនុវត្តតាមខ្លឹមសារដែលមានចែងក្នុងសៀវភៅគោលការណ៍ណែនាំស្តីពីសុវត្ថិភាព និងសុខភាពនៅការដ្ឋានសំណង់។

៧. ត្រូវសុំការអនុញ្ញាតជាមុនពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងករណីមានការកែប្រែមុខងារអគារ សោភណភាពអគារ ឬការសាងសង់បន្ថែមផ្សេងៗ។

៨. បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតសាងសង់ ត្រូវស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ជាមុនពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយផ្អែកលើលក្ខខណ្ឌផ្សេងៗ ដូចមានចែងក្នុងប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ ។

៩. ត្រូវសហការជាមួយមន្ត្រីជំនាញរបស់ក្រសួងចុះបោះបង្គោលកំណត់ព្រំទីតាំងសំណង់ក្នុងដីឡូត៍ឱ្យបានត្រឹមត្រូវស្របតាមលិខិតអនុញ្ញាតសាងសង់ និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់នៅមុនពេលដំណើរការសាងសង់។

១០. ក្នុងករណីការដ្ឋានដំណើរការសាងសង់មុនទទួលបានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ការដ្ឋានសាងសង់ត្រូវបានផ្អាកជាបណ្តោះអាសន្ន រហូតដល់ទទួលបានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ។ ក្នុងករណីមិនអនុវត្តតាមការណែនាំ នៅតែបន្តការសាងសង់ ម្ចាស់សំណង់អាចប្រឈមមុខទៅនឹងវិធានការដកហូតសម្ភារៈសាងសង់ និងអាចត្រូវបានប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន ។

១១. ត្រូវសុំលិខិតបិទការដ្ឋានសំណង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោយពីបានបញ្ចប់ការសាងសង់។

លិខិតអនុញ្ញាតសាងសង់នឹងត្រូវអស់សុពលភាព បើការងារសាងសង់ពុំត្រូវបានដំណើរការក្នុងរយៈពេល ១ (មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ប៉ែន សុផល**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងបរិស្ថាន

-ក្រសួងរ៉ែ និងថាមពល

-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

-អគ្គស្នងការដ្ឋាននគរបាលជាតិ

-រដ្ឋបាលរាជធានីភ្នំពេញ

-អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម

-អគ្គនាយកដ្ឋានសំណង់

-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ

-មន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ

-ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ខណ្ឌសុខសែន

-ការិយាល័យបង្ការ និងពន្លត់អគ្គិភ័យ នៃស្នងការដ្ឋាននគរបាល រាជធានីភ្នំពេញ

-ឯកសារ-កាលប្បវត្តិ